គណៈកម្មាធិការប្រជាជន

ខេត្តត្រាវិញ

**<u>សាកលវិទ្យាល័យត្រាវិញ</u>**

លេខៈ /KH-ĐHTV

**សាធារណរដ្ឋសង្គមនិយមវៀតណាម**

**ឯករាជ្យ-សេរីភាព-សុភមង្គល**

*ត្រាវិញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧*

# ផែនការ

## ជម្រើសនិស្សិតកំរិតបរិញ្ញាបត្រប្រមូលផ្ដុំបែបពេញម៉ោង សម្រាប់សិស្ស-និស្សិតកម្ពុជានាឆ្នាំ២០១៧

យោងតាមសារាចរលេខ 05/2017/TT – BGDĐT ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ របស់រដ្ឋមន្ត្រីក្រសួងអប់រំនិងបណ្តុះបណ្តាល ស្តីអំពីការកែប្រែ បំពេញបន្ថែមនូវមាត្រាមួយចំនួនក្នុងបែបបទជ្រើសរើសនិស្សិតកំរិតបរិញ្ញាបត្រ បរិញ្ញាបត្ររងបែបពេញម៉ោង។

យោងតាមមុខងារ ភារកិច្ច លទ្ធភាពបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យត្រាវិញ និងតម្រូវការរបស់អ្នករៀន ពិសេសគឺសិស្ស-និស្សិតកម្ពុជាក្នុងដំណាក់កាលបច្ចុប្បន្ន។

សាកលវិទ្យាល័យត្រាវិញបានចងក្រងនូវគម្រោងជម្រើសនិស្សិតកំរិតបរិញ្ញាបែបពេញម៉ោងសម្រាប់សិស្ស-និស្សិតកម្ពុជា នាឆ្នាំ២០១៧មានដូចតទៅៈ

### I. វត្ថុបំណង

អនុវត្តគោលការណ៍របស់បក្សនិងរដ្ឋបើកទូលាយទម្រង់ជ្រើសរើសនិស្សិតឈានដល់សមាហរណកម្មនិងអភិវឌ្ឍន៍។

អនុវត្តតាមបាវចនៈរបស់សាលាគឺ*«នាំមកនូវឱកាសសិក្សាមានគុណភាពសម្រាប់សហគមន៍»*។

បើកទូលាយសកម្មភាព បង្កើនចំណងមិត្តភាព សហការលើគ្រប់ជ្រុងជ្រោយ រួមគ្នាអភិវឌ្ឍន៍ អនុវត្តទៅតាមទស្សនរបស់ថ្នាក់ដឹកនាំ ក៏ដូចជាបំណងរបស់ប្រជាជននៃប្រទេសទាំងពីរវៀតណាម-កម្ពុជា។

អនុវត្តទៅតាមបទដ្ឋានបទកំណត់ជាធរមានរបស់ប្រទេសវៀតណាម-កម្ពុជា។

បង្គលក្ខណៈសមស្របសម្រាប់សិស្ស-និស្សិតកម្ពុជាមកសិក្សានៅសាកលវិទ្យាល័យត្រាវិញ ដែលជាមជ្ឈដ្ឋានសិក្សាទំនើបនិងសកម្ម។

បង្កនូវអារម្មណ៍ល្អដល់សហគមន៍និងបណ្តាស្ថាប័នក្នុងនិងក្រៅប្រទេសអំពីសាកលវិទ្យាល័យត្រាវិញ។

**II. កម្មវត្ថុអនុវត្ត**

*១/ មុខជំនាញជ្រើសរើសនិងបណ្តុះបណ្តាលសម្រាប់និស្សិតកម្ពុជា*

| **លេខកូដ** | **កំរិតបរិញ្ញាបត្រ** | **លេខកូដ** | **កំរិតបរិញ្ញាបត្ររង** |
|---|---|---|---|
| 51340301 | គណនេយ្យ | 6340301 | គណនេយ្យ |
| 51340101 | គ្រប់គ្រងពាណិជ្ជកម្ម | 6340114 | គ្រប់គ្រងពាណិជ្ជកម្ម |
| 51340201 | ហិរញ្ញវត្ថុ-ធនាគារ | 6220103 | វៀតណាមវិទ្យា |
| 51310101 | សេដ្ឋកិច្ច | 6220206 | ភាសាអង់គ្លេស |
| 51380101 | នីតិសាស្ត្រ | 52140201 | អប់រំមត្តេយ្យ |
| 51220201 | ភាសាអង់គ្លេស | 6640203 | បសុពេទ្យ |
| 51140201 | អប់រំមត្តេយ្យ | 6480201 | ព័ត៌មានវិទ្យា |
| 51620101 | កសិកម្ម | 6510303 | បច្ចេកវិទ្យាអគ្គិសនី-អេឡិចត្រូណិច |
| 51640101 | បសុពេទ្យ | | |
| 51480201 | ព័ត៌មានវិទ្យា | 6510104 | បច្ចេកវិទ្យាសាងសង់សំណង់ |
| 51510301 | បច្ចេកវិទ្យាអគ្គិសនី-អេឡិចត្រូណិច | 6510201 | បច្ចេកវិទ្យាមេកានិក |
| 51510102 | បច្ចេកវិទ្យាសាងសង់សំណង់ | 6720501 | ថែទាំជម្ងឺ |
| 51510201 | បច្ចេកវិទ្យាមេកានិក | 6720306 | តេស្តវេជ្ជសាស្ត្រ |
| 51510401 | បច្ចេកវិទ្យាគីមីសាស្ត្រ | 6720401 | ឱសថ |

| | | | |
|---|---|---|---|
| 51720501 | ថែទាំជម្ងឺ | | |
| 51720332 | តេស្តវេជ្ជសាស្ត្រ | | |
| 51720101 | ពហុវេជ្ជសាស្ត្រ | | |
| 51720301 | សុខាភិបាលសាធារណៈ | | |
| 51720601 | ពេទ្យធ្មេញ | | |
| 51720401 | ឱសថ | | |

*២. វិធីជ្រើសរើស*

ជ្រើសតាមបទកំណត់ចេញជាធរមាន។ បេក្ខជនមួយរូបៗ ត្រូវដាក់ពាក្យ តាមសំណុំបែបបទគំរូរបស់សាកលវិទ្យាល័យត្រាវិញ។

វិធីជ្រើសរើសមាន២ គឺជ្រើសតាមពិន្ទុប្រឡងបញ្ចប់ទុតិយភូមិ និងពិន្ទុឆ្នាំសិក្សាថ្នាក់ទី១២។

*៣. រយៈពេលជ្រើសរើស*

- គ្រោងនឹងជ្រើសរើសចាប់ពីថ្ងៃទី១០ ខែសីហា ដល់ ៣០ ខែកញ្ញា ឆ្នាំ២០១៧។

- ប្រកាសលទ្ធផលមុនថ្ងៃទី២០ តុលា ឆ្នាំ២០១៧។

- ជួបជុំនិស្សិតជាប់ឈ្មោះនិងបើកបវេសនកាលមុនថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១៧។

***៤. គម្រោងបណ្តុះបណ្តាល៖*** អនុវត្តគម្រោងបណ្តុះបណ្តាលពីរដំណាក់កាល

***- ដំណាក់កាលទី១៖*** សិក្សាភាសា-វប្បធម៌វៀតណាម និងសិក្សានូវមុខវិជ្ជាមូលដ្ឋានចំពោះបណ្តាឯកទេសនឹងបណ្តុះបណ្តាល។ ក្នុងរយៈពេល ១ឆ្នាំ។

***- ដំណាក់កាលទី២៖*** បណ្តុះបណ្តាលតាម ជំនាញឯកទេសដែលបេក្ខសិស្សជ្រើសរៀន។ ក្នុងដំណាក់កាលនេះនិស្សិតកម្ពុជានឹងបានសិក្សាជាមួយនឹងនិស្សិតវៀតណាម(រយៈពេល៤ឆ្នាំ ឬ ៦ឆ្នាំ)។

រយៈពេលសិក្សាកំរិតបរិញ្ញាបត្រគឺ៥ឆ្នាំទៅ ៧ឆ្នាំ ចំពោះបរិញ្ញាបត្ររងគឺ ៤ឆ្នាំ។

*៥. តម្លៃសិក្សា*

***៥-១ តម្លៃសិក្សាឆ្នាំទី១*** (ឆ្នាំសិក្សា២០១៧-២០១៨)គឺ ៩.៥០០.០០០ ដុង/បេក្ខសិស្ស/ឆ្នាំ ស្មើនិង ២០០ដុល្លា។ តម្លៃសិក្សានេះអនុវត្តចំពោះកំរិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររង។

***៥-២ តម្លៃសិក្សាឆ្នាំទី២***

*តម្លៃសិក្សាឆ្នាំ ២០១៨-២០១៩

| | **ជំនាញឯកទេសបរិញ្ញាបត្រ** | **តម្លៃសិក្សា** |
|---|---|---|
| ១ | គណនេយ្យ | ១៥ ៧០០ ០០០ដុង/ឆ្នាំ (ស្មើនិង ៦៨០ដុល្លា/ឆ្នាំ) |
| ២ | គ្រប់គ្រងពាណិជ្ជកម្ម | |
| ៣ | ហិរញ្ញវត្ថុ-ធនាគារ | |
| ៤ | សេដ្ឋកិច្ច | |
| ៥ | នីតិសាស្ត្រ | |
| ៦ | ភាសាអង់គ្លេស | |
| ៧ | អប់រំមត្តេយ្យ | |
| ៨ | កសិកម្ម | |
| ៩ | បសុពេទ្យ | ១៩ ២០០ ០០០ ដុង/ឆ្នាំ (ស្មើនិង ៨៣៥ដុល្លា/ឆ្នាំ) |
| ១០ | បច្ចេកវិទ្យាគីមីសាស្ត្រ | |
| ១១ | បច្ចេកវិទ្យាអគ្គិសនី-អេឡិចត្រូណិច | ១៧ ៥០០ ០០០ដុង/ឆ្នាំ (ស្មើនិង ៧៦០ដុល្លា/ឆ្នាំ) |
| ១២ | បច្ចេកវិទ្យាសាងសង់ | |
| ១៣ | បច្ចេកវិទ្យាមេកានិក | |
| ១៤ | ព័ត៌មានវិទ្យា | |
| ១៥ | ថែទាំជម្ងឺ | ២៦ ២៥០ ០០០ដុង/ឆ្នាំ (ស្មើនិង១១៤៥ដុល្លា/ឆ្នាំ) |
| ១៦ | តេស្តវេជ្ជសាស្ត្រ | |
| ១៧ | ឱសថ | |

| | | |
|---|---|---|
| ១៨ | សុខាភិបាល សាធារណៈ | |
| ១៩<br>២០ | ពហុវេជ្ជសាស្ត្រ<br>ពេទ្យធ្មេញ | ៣១ ៥០០ ០០០ដុង/ឆ្នាំ<br>(ស្មើនិង ១៣៧០ដុល្លា/ឆ្នាំ) |
| **បរិញ្ញាបត្ររង** | | |
| **តម្លៃសិក្សាចំពោះកំរិតបរិញ្ញាបត្ររង ស្មើនឹង ៨០% កំរិតបរិញ្ញាបត្រ។** | | |

* ចាប់ពីឆ្នាំទី៣ឡើងទៅ ក្នុងមួយឆ្នាំៗ តម្លៃសិក្សានឹងបង្កើនបន្ថែម ១៥% ចំពោះតម្លៃឆ្នាំមុន(តម្លៃបន្ថែមនេះអនុវត្តឱ្យបណ្តាមុខជំនាញឯកទេសសិក្សា)។

**III. វិធានការអនុវត្ត**

សាកលវិទ្យាល័យត្រាវិញបង្កើតក្រុមប្រឹក្សាជំរើសនិស្សិតនៅកម្ពុជាដើម្បីធ្វើកិច្ចការផ្សព្វផ្សាយឃោសនាប្រឹក្សាជំរើសនិស្សិតនៅកម្ពុជា។ សាកលវិទ្យាល័យត្រាវិញបានជ្រើសរើសបញ្ជូនសមាជិកសាលា ជាអ្នកទទួលភារកិច្ចផ្ទាល់ និងអញ្ជើញក្រុមគ្រូបង្រៀននិស្សិតវៀតណាមដែលកំពុងសិក្សានៅកម្ពុជា ព្រមជាមួយនឹងអញ្ជើញនិស្សិតកម្ពុជាមួយចំនួនធ្វើជាសមាជិកដើម្បីធ្វើការផ្សព្វផ្សាយតាមបណ្តាសាលាវិទ្យាល័យផ្សេងៗជាពិសេសនៅបណ្តាខេត្តជាប់ព្រំដែន។

សាកលវិទ្យាល័យត្រាវិញសង្ឃឹមក្រសួងអប់រំយុវជននិងកីឡានៃព្រះរាជាណាចក្រកម្ពុជាឧត្តម្ភគាំទ្រ ផ្សព្វផ្សាយដល់បណ្តាមន្ទីរអប់រំនៃបណ្តាខេត្តក្រុង ក៏ដូចជាបណ្តាសាលាវិទ្យាល័យទូទាំងប្រទេស។

ខាងលើនេះគឺជាផែនការនៃកិច្ចការជ្រើសរើសនិស្សិតនៅកម្ពុជានាឆ្នាំ២០១៧។ សាកលវិទ្យាល័យត្រាវិញសូមគោរពផ្ញើក្រសួងអប់រំយុវជននិងកីឡានៃព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាប និងឧបត្ថម្ភសហការ។

***កន្លែងទទួលៈ*** **សាកលវិទ្យាធិការ**

- ក្រសួងអប់រំ យុវជន និងកីឡាព្រះរាជាណាចក្រកម្ពុជា;

- គណៈកម្មការសាលា;

- បណ្ដាសមាជិក អង្គភាពដែលពាក់ព័ន្ធ;

-រក្សានៅៈការិយាល័យរដ្ឋបាលក្រុមប្រឹក្សាជ្រើសរើសនិស្សិត។

**ថាច់ ធី យ៉ឺន**